# សេចក្តីជូនដំណឹង

## គម្រោង TRADE 2006-2010 រួមចំណែកកាត់បន្ថយភាពក្រីក្រ

**កម្មវិធី :** សិក្ខាសាលាបង្ហាញសមិទ្ធផលនៃគម្រោង ត្រេត/TRADE

**ក្រោមអធិបតីភាព :** ឯកឧត្តម **ចម ប្រសិទ្ធ** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ឯកឧត្តម **ប៉ាន សូរាសក្តិ** រដ្ឋលេខាធិការ ក្រសួងពាណិជ្ជកម្ម

លោកស្រី **អេឡេណា ទីវេនកូ** នាយិកាការិយាល័យ យូអិនឌីភី ប្រចាំកម្ពុជា

**ពេលវេលា :** ថ្ងៃព្រហស្បតិ៍ ទី ២៧ ខែ មករា ឆ្នាំ ២០១១ វេលាម៉ោង ៨:៤៥ ព្រឹក - ១២:៣០ រសៀល

**ទីកន្លែង :** ក្រសួងពាណិជ្ជកម្ម ដីឡូតិ៍លេខ ១៩-៦១ ផ្លូវក្រសួងពាណិជ្ជកម្ម (ផ្លូវលេខ ១១៣B), ភូមិទឹកថ្លា សង្កាត់សែន សុខ រាជធានីភ្នំពេញ

---

**ជម្រាបមកអ្នកសារព័ត៌មាន/និពន្ធនាយក!**

យើងសូមអញ្ជើញលោក លោកស្រី ចូលរួមយកព័ត៌មានក្នុងសិក្ខាសាលាខាងលើ ដែលនឹងបង្ហាញអំពីសមិទ្ធផល ការប្រឈម និងបទពិសោធន៍ ពីគម្រោងជំនួយពាណិជ្ជកម្មដើម្បីការអភិវឌ្ឍន៍ និងសមធម៌ (Trade-Related Assistance for Development and Equity/TRADE) ។

ចាប់ពីឆ្នាំ ២០០៦ មក គម្រោង ត្រេត/TRADE ត្រូវបានអនុវត្តដោយក្រសួងពាណិជ្ជកម្ម ក្រោមការគាំទ្រពីកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (យូអិនឌីភី) ។

គម្រោង ត្រេត/TRADE បានជួយធ្វើឱ្យកម្ពុជាស្ថិតក្នុងចំណោមប្រទេសជួរមុខដែលប្រឹងប្រែងនៅក្នុងការប្រើប្រាស់ពាណិជ្ជកម្មអន្តរជាតិសម្រាប់ជាកត្តាជម្រុញដើម្បីកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍមនុស្ស។ គោលដៅចំបងមួយផ្សេងទៀតនៃគម្រោងនេះ គឺពង្រឹងសមត្ថភាពនាំចេញរបស់កម្ពុជានៅក្នុងវិស័យជាយុទ្ធសាស្ត្រមួយចំនួន។ ដោយឡែក គម្រោងនេះបានធ្វើការជាមួយសហគ្រាសកិនស្រូវ និងមន្ត្រីរដ្ឋាភិបាល ដើម្បីស្វែងរកទីផ្សារថ្មីៗសម្រាប់អង្ករ ដែលនាំឱ្យមានបេសកកម្មមួយខាងពាណិជ្ជកម្ម ទៅសហភាពអឺរ៉ុប និងអាហ្រ្វិកខាងលិច ផង។

ឯកឧត្តម **ចម ប្រសិទ្ធ** ទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម នឹងធ្វើជាអធិបតីនៅក្នុងពិធីនេះ និងថ្លែងសន្ទរកថាគូសបញ្ជាក់អំពីសមិទ្ធផល ការប្រឈមនិងបទពិសោធន៍ដែលទទួលបានពីគម្រោងនេះ។

ចំពោះព័ត៌មានបន្ថែម សូមទាក់ទង :

**ក្រសួងពាណិជ្ជកម្ម** : លោក សួន ប្រសិទ្ធ អនុប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ ទូរស័ព្ទ: ០១២ ៩៤២ ៧៧៧, prasithsuon@gmail.com

**យូអិនឌីភី** : កែ មុនធិត ទូរស័ព្ទ : ០១១ ៩០៥ ២៦១, munthit.ker@undp.org.